ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ..................................................

# សុន្ទរកថា

## លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងសិក្ខាសាលាស្តីពី ប្រាក់រៀល ប្រព័ន្ធបាគង និងខេអេចឃ្យូអរ (KHQR)
## ក្នុងឱកាសខួបលើកទី៤៥ នៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ

ថ្ងៃព្រហស្បតិ៍ ៧រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៥ នៅវិមានរដ្ឋសភា

៣៣៣✶៤៤៤

ជាបឋម នាងខ្ញុំសូមគោរព៖

- ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប អនុប្រធានទី១ នៃរដ្ឋសភា និងជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា
- ឯកឧត្តម ធន់ វឌ្ឍនា អនុប្រធានទី២ នៃព្រឹទ្ធសភា
- ឯកឧត្តម ឈាង វុន ប្រធានគណៈកម្មការទី២ នៃរដ្ឋសភា
- ឯកឧត្តម លោកជំទាវ ប្រធាននិងអនុប្រធានគណៈកម្មាការ សមាជិក សមាជិកានៃព្រឹទ្ធសភា និងរដ្ឋសភា
- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីគោរព!

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយនិងកិត្តិយសជាអនេក ដែលធនាគារជាតិនៃកម្ពុជា បានសហការជាមួយរដ្ឋសភានិងព្រឹទ្ធសភា រៀបចំសិក្ខាសាលាស្តីពីប្រាក់រៀល ប្រព័ន្ធទូទាត់បាគង និង KHQR ក្នុងឱកាសដ៏វិសេសវិសាលនៃការអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៥ នៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ (២០មីនា ១៩៨០ - ២០មីនា ២០២៥)។ នាងខ្ញុំសូមសម្តែងអំណរគុណយ៉ាងខ្ពង់ខ្ពស់ចំពោះ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា** ដែលបានអនុញ្ញាតឱ្យមានកិច្ចសហការរៀបចំពិធីជាប្រវត្តិសាស្ត្រជាតិនេះឡើងនៅវិមានរដ្ឋសភា។ នាងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប អនុប្រធានទី១ នៃរដ្ឋសភា និងជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចមហារដ្ឋសភាធិការធិបតី ប្រធានរដ្ឋសភា ឯកឧត្តម ធន់ វឌ្ឍនា អនុប្រធានទី២ នៃព្រឹទ្ធសភា ឯកឧត្តម ឈាង វុន ប្រធានគណៈកម្មការទី២ នៃរដ្ឋសភា** ដែលបានឆ្លៀតឱកាសដ៏មមាញឹកចូលរួមជាអធិបតីនាព្រឹកនេះ និងសូមថ្លែងអំណរគុណចំពោះឯកឧត្តម លោកជំទាវ ជាសមាជិក



ប្រអប់សំបុត្រលេខ ២៥, ផ្ទះលេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

សមាជិកាព្រឹទ្ធសភា រដ្ឋសភា ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាតំណាងក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងភ្ញៀវកិត្តិយសទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងសិក្ខាសាលានាពេលនេះ។

វត្តមានដ៏ឧត្តុងឧត្តមរបស់គណៈអធិបតី និងឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់នាព្រឹកនេះ ពិតជាញ៉ាំងឱ្យសិក្ខាសាលា និងការអបអរសាទរទិវាប្រាក់រៀលនាឆ្នាំនេះ មានភាពវិសេសវិសាលនិងប្រព្រឹត្តិទៅប្រកបដោយភាពឱឡារិក និងអធិកអធមជាមួយការចងចាំ និងអត្ថន័យដ៏ជ្រាលជ្រៅបំផុត។ ជាការពិតណាស់ កាលពី ៤៥ ឆ្នាំមុន ប្រាក់រៀលត្រូវបានដាក់ឱ្យចរាចរឡើងវិញ ដើម្បីរួមចំណែកពង្រឹងអត្តសញ្ញាណជាតិ អធិបតេយ្យជាតិ និងគាំទ្រដំណើរការស្តារសេដ្ឋកិច្ច ចេញពីបាតដៃទទេ ក្រោយពីរបបប៉ុល ពត ដែលបំផ្លាញនូវរាល់យឿនសេដ្ឋកិច្ចនិងសង្គមជាតិ។

ដោយសារការអូសបន្លាយនៃសង្គ្រាមស៊ីវិលអស់រយៈពេលជិត ៣ ទសវត្សរ៍ ហើយជាពិសេសរបបប៉ុល ពត បានលុបបំបាត់ប្រាក់រៀលមិនឱ្យចរាចរទៀតនោះ ទំនុកចិត្តមកលើប្រាក់រៀលបានបាត់បង់ទាំងស្រុង ការស្តារទំនុកចិត្តនេះឡើងវិញ គឺជាការលំបាកបំផុត។ លើសពីនេះ ការហូរចូលនៃប្រាក់ដុល្លារអាមេរិកយ៉ាងសន្ធឹកសន្ធាប់ នាដើមទសវត្សរ៍ឆ្នាំ១៩៩០ បានធ្វើឱ្យប្រជាពលរដ្ឋកម្ពុជា ទទួលយកប្រាក់ដុល្លារអាមេរិកមកប្រើប្រាស់នៅក្នុងជីវភាពប្រចាំថ្ងៃ។ ទោះយ៉ាងណា នារយៈពេលជាង ២ទសវត្សរ៍ចុងក្រោយនេះ ក្រោមដំបូលសុខសន្តិភាព ដែលទទួលបានពីនយោបាយឈ្នះ-ឈ្នះ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា និងជាអតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** សេដ្ឋកិច្ចមានវឌ្ឍនភាពយ៉ាងឆាប់រហ័សលើគ្រប់វិស័យ ហើយតម្លៃប្រាក់រៀលក៏មានស្ថិរភាពយ៉ាងល្អប្រសើរ ជាមួយកម្រិតទាបនៃអតិផរណា។

ការរក្សាបានសន្តិភាព ស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច គឺជាបុរេលក្ខខណ្ឌមូលដ្ឋាន ដែលបានស្តារជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀលឡើងវិញ។ ក្នុងន័យនេះ ការរក្សាបានស្ថេរភាពអត្រាប្តូរប្រាក់រៀលទៅដុល្លារមានសារៈសំខាន់បំផុតដើម្បីជម្រុញទំនុកចិត្តនេះ។ ក្រោមការគ្រប់គ្រងប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់ **ឯកឧត្តម ជា ចាន់តូ** អតីតទេសាភិបាលធនាគារជាតិនៃកម្ពុជា អត្រាប្តូរប្រាក់រៀលបានរក្សាស្ថេរភាពត្រឹមរង្វង់ ៤.០៥០រៀលក្នុង១ដុល្លារអាមេរិក ចាប់តាំងពីឆ្នាំ១៩៩៨ ដែលឯកឧត្តមបានចូលកាន់តំណែងទេសាភិបាលមក។ លើសពីនេះ ការអនុវត្តគោលនយោបាយមួយចំនួនក្នុងការគាំទ្រប្រាក់រៀល ក៏បានចេញផ្លែផ្កាជាបន្តបន្ទាប់។ ជាក់ស្តែង ប្រាក់រៀលក្នុងចរាចរណ៍បានកើនឡើងក្នុងអត្រាជាមធ្យម ១៥% ក្នុង១ឆ្នាំ នារយៈពេលជាង២ទសវត្សរ៍កន្លងមកនេះ។ នៅក្នុង

ប្រព័ន្ធធនាគារវិញ សមាមាត្រឥណទានជាប្រាក់រៀលបានកើនដល់ ១៣,៤% នៃទំហំឥណទានសរុប ខ្ពស់ជាងកម្រិតកំណត់អប្បបរមា ១០% ស្របពេលដែលប្រាក់បញ្ញើជារៀលបានកើនឡើងដល់ ១១,៤% នៃប្រាក់បញ្ញើសរុប ពីត្រឹម ៥,៥% កាលពី ១០ឆ្នាំមុន ដែលសរបញ្ជាក់ពីការទទួលស្គាល់របស់សាធារណៈលើតម្លៃប្រាក់រៀលជាឧបករណ៍សន្សំ។

ទោះយ៉ាងណា កំណើននៃចរាចរណ៍ប្រាក់រៀល ក៏បានកើតឡើង ទន្ទឹមនឹងការកើនឡើងនៃចរាចរណ៍ប្រាក់ដុល្លារអាមេរិកផងដែរ ដែលធ្វើឱ្យកម្រិតដុល្លាវូបនីយកម្មនៅទ្រឹងក្នុងរយៈពេលជាង ១ ទសវត្សរ៍ចុងក្រោយនេះ។ តាមការសិក្សាស្រាវជ្រាវកន្លងមក ជាពិសេសក្រោមកិច្ចសហការជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ IMF និង ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន JICA កម្រិតដុល្លាវូបនីយកម្មត្រូវបានរំពឹងថានឹងបន្តមានកម្រិតខ្ពស់ ដោយសារតែចំណូលជាប្រាក់ដុល្លារ ដែលទទួលបានពីលំហូរចូលនៃការវិនិយោគ ពាណិជ្ជកម្ម និងទេសចរណ៍ ជាដើមនោះ ត្រូវបានប្រើប្រាស់ដោយគ្មានការប្តូរ រួមនឹងភាពខ្វះកិច្ចខិតខំប្រឹងប្រែងក្នុងការលើកម្ពស់ការប្រើប្រាស់ប្រាក់រៀល ប្រកបដោយសង្គតិភាព។ ការសិក្សាទាំងនេះ ក៏បង្ហាញដែរថាកិច្ចសហការពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដើរតួនាទីមិនអាចខ្វះបាន ក្នុងការជំរុញប្រាក់រៀលឱ្យចរាចរកាន់តែច្រើននិងទូលំទូលាយដោយនិរន្តរភាព។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ការប្រើប្រាស់ដុល្លារអាមេរិកនៅតែមានសារៈសំខាន់ នៅក្នុងសេដ្ឋកិច្ចកម្ពុជា ដោយបានគាំទ្រដល់ពាណិជ្ជកម្មនិងការវិនិយោគនៅកម្ពុជា ជាពិសេសនាគ្រាដំបូងនៃការចាប់ផ្តើមអភិវឌ្ឍសេដ្ឋកិច្ច។ ក៏ប៉ុន្តែ នៅពេលដែលសេដ្ឋកិច្ចកម្ពុជាកាន់តែរីកចម្រើននិងមានភាពប្រទាក់ក្រឡាខ្ពស់ ការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកយ៉ាងទូលំទូលាយ ដូចពេលបច្ចុប្បន្នពិតជានាំឱ្យកម្ពុជាមានភាពងាយរងគ្រោះ ជាពិសេសក្នុងពេលមានវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្នុងពេលនៃភាពមិនប្រាកដប្រជានៃនយោបាយសហរដ្ឋអាមេរិក ការបែងខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ច និន្នាការសមាហរណកម្មតំបន់ និងនិន្នាការបដិដុល្លាវូបនីយកម្មក្នុងពិភពលោក។ យ៉ាងណាមិញ ការឆ្លងកាត់វិបត្តិកូវីដ-១៩ កន្លងមក បង្ហាញថា កម្ពុជាមិនអាចពឹងផ្អែកដោយពេញលេញលើនយោបាយរូបិយវត្ថុខ្លួន ក្នុងការរួមចំណែកកាត់បន្ថយអាត្រាការប្រាក់ និងបញ្ចេញសន្ទនីយភាពច្រើន ដើម្បីជំរុញដំណើរការសេដ្ឋកិច្ចឡើងវិញបានទេ។ បញ្ហានេះ គឺដោយសារនយោបាយរូបិយវត្ថុមានឥទ្ធិពលតែទៅលើប្រាក់រៀលប៉ុណ្ណោះ ហើយក្នុងស្ថានភាពដុល្លាវូបនីយកម្មនៅខ្ពស់ ឥទ្ធិពលនេះត្រូវបានកំហិត ដោយនយោបាយរូបិយវត្ថុសហរដ្ឋអាមេរិក។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជាមិនអាចបន្ថយអត្រាការប្រាក់ជាដុល្លារអាមេរិក ឬប្រាក់រៀលបានទេ ល្គឹកណា អត្រាការប្រាក់គោលរបស់សហរដ្ឋអាមេរិកមានកម្រិតខ្ពស់។

កន្លងមក ធនាគារជាតិនៃកម្ពុជា បានសហការស្រាវជ្រាវជាមួយស្ថាប័នអន្តរជាតិជាច្រើន លើការលើកកម្ពស់រូបិយវត្ថុជាតិ ដោយវិភាគយ៉ាងល់អិតនិងស៊ីជម្រៅលើផលចំណេញនិងគុណវិបត្តិនៃបដិដុល្លារូបនីយកម្ម ក្នុងគោលដៅធ្វើយ៉ាងណាជំរុញការប្រើប្រាស់ប្រាក់រៀលដោយពិលាស និងមិនធ្វើឱ្យប៉ះពាល់ដល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ នាឆ្នាំនេះ ធនាគារជាតិនៃកម្ពុជា បានពង្រីកកិច្ចសហការស្រាវជ្រាវជាមួយរដ្ឋសភាជាតិលើប្រធានបទ តួនាទីរបស់ស្ថាប័នសាធារណៈក្នុងការជំរុញការប្រើប្រាស់ប្រាស់ប្រាក់រៀល និងគ្រោងបញ្ចប់ការស្រាវជ្រាវនាដើមឆមាសទី២ ខាងមុខ។ លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ មាននៅក្នុងគេហទំព័រធនាគារជាតិនៃកម្ពុជា។

ខ្ញុំសូមថ្លែងអំណរគុណ ចំពោះក្រុមស្រាវជ្រាវរដ្ឋសភានិងធនាគារជាតិនៃកម្ពុជា ដែលបានរួមចំណែកក្នុងការស្រាវជ្រាវដ៏មានសារៈសំខាន់នេះ ដែលកន្លងមកធនាគារជាតិនៃកម្ពុជា បានសហការសិក្សាតែទៅលើវិស័យឯកជន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ការស្រាវជ្រាវនេះនឹងផ្តល់ធាតុចូលយ៉ាងសំខាន់ លើការរៀបចំគោលនយោបាយលើកកម្ពស់ប្រាក់រៀលរបស់រាជរដ្ឋាភិបាលប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងស៊ីជម្រៅ។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ការជម្រុញការប្រើប្រាស់ប្រាក់រៀលទាមទារឱ្យមានការច្នៃប្រឌិតទាំងលើទិដ្ឋភាពគោលនយោបាយ និងបច្ចេកវិទ្យា។ ជាក់ស្តែង សិក្ខាសាលារបស់យើង ក៏ពិភាក្សាពីការអភិវឌ្ឍប្រព័ន្ធទូទាត់បាគង និង KHQR ដែលកម្ពុជាសម្រេចបានលទ្ធផលគួរជាទីមោទនៈក្នុងការគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសមាហរណកម្មក្នុងតំបន់និងពិភពលោក។ កន្លងមកមជ្ឈដ្ឋានអន្តរជាតិ បានទទួលស្គាល់ពីតួនាទីដ៏សំខាន់នៃប្រព័ន្ធទូទាត់ដ៏ទំនើបនេះ ហើយបានមកសិក្សារៀនសូត្រពីកម្ពុជា ជាពិសេស លើការរួមចំណែករបស់ប្រព័ន្ធទូទាត់ ក្នុងការជំរុញបរិយាបន្នហិរញ្ញវត្ថុ សុវត្ថិភាពនិងប្រសិទ្ធភាពនៃការទូទាត់ និងការតភ្ជាប់ជាមួយនឹងបណ្តាញទូទាត់អន្តរជាតិផងដែរ។ ជាក់ស្តែង ការទូទាត់តាមប្រព័ន្ធបាគង បានកើនឡើងយ៉ាងឆាប់រហ័ស ចាប់តាំងពីការដាក់ឱ្យប្រើប្រាស់កាលពីឆ្នាំ២០២០មក ដែលក្នុងឆ្នាំ២០២៤ ប្រតិបត្តិការទូទាត់សរុបមានចំនួន ៦០៧,៥លានប្រតិបត្តិការ ដោយក្នុងនោះទំហំទឹកប្រាក់នៃប្រតិបត្តិការជាលុយរៀលមានចំនួន ១៨៣,៣ទ្រីលានរៀល និងជាដុល្លារអាមេរិកមានចំនួន ១០៤,៨ប៊ីលានដុល្លារ ហើយមានចំនួនគណនីប្រើប្រាស់ចំនួន ៣០លានគណនី ដែលអាចទូទាត់បានជាមួយនឹងពាណិជ្ជករក្នុងស្រុកចំនួន ៤,៥លានកន្លែង និងក្រៅស្រុកច្រើនជាង ៥០លានកន្លែង ដូចជានៅប្រទេសថៃ វៀតណាម ឡាវ ម៉ាឡេស៊ី និងចិន និងអនុញ្ញាតឱ្យភ្ញៀវទេសចរពីប្រទេសទាំងនោះអាចមកទូទាត់នៅតាម KHQR នៅកម្ពុជាបានយ៉ាងងាយស្រួល

ភាពងាយស្រួលនៃការទូទាត់តាមទូរសព្ទបានជម្រុញប្រជាជន អ្នកលក់ដូរជាច្រើនទៅបើកគណនីធនាគារដើម្បីទទួលការទូទាត់ ដែលការណ៍នេះសម្រួលដល់ជីវភាព និងសុវត្ថិភាពរបស់គាត់។ អាជីវករនិងប្រជាជនដែលមានបំណង់ទូទាត់ឆ្លងប្រទេសត្រូវបើកគណនីជាប្រាក់រៀលទើបអាចធ្វើបាន ដែលការណ៍នេះក៏បានជម្រុញការប្រើប្រាស់ប្រាក់រៀលជាលំដាប់។ ថ្មីៗនេះ ធនាគារជាតិនៃកម្ពុជា បានដាក់ឱ្យប្រើប្រាស់កម្មវិធីទូទាត់ "បាគងទេសចរ" ដែលភ្ញៀវទេសចរបរទេស អាចទូទាត់ជាប្រាក់រៀលតាមប្រព័ន្ធទូទាត់ឌីជីថលបានយ៉ាងឆាប់រហ័ស និងសុវត្ថិភាព ដោយគ្រាន់តែបញ្ចូលលុយទៅក្នុងគណនីកាបូបអេឡិចត្រូនិក តាមរយៈ Visa Mastercard ឬ UnionPay ហើយធ្វើការទូទាត់នៅគ្រប់អាជីវករទូទាំងប្រទេស ដែលប្រើប្រព័ន្ធបាគង។

ខ្ញុំជឿជាក់ថា ម្លប់សន្តិភាពដ៏រឹងមាំនឹងអនុញ្ញាតឱ្យកម្ពុជាសម្រេចបានសមិទ្ធផលជាច្រើនបន្តបន្ទាប់ទៀត ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ទាំងអស់ សូមជួបប្រទះពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**